ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**
សំណុំរឿងព្រហ្មទណ្ឌលេខ ០៤៨
ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១
សាលក្រមលេខ ០៧ (ក)/១២
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តឧត្តរមានជ័យ**

បានបើកសវនាការជាសាធារណៈ នៅសាលជម្រះក្តីនៃសាលាដំបូងខេត្តឧត្តរមានជ័យនាថ្ងៃអង្គារ ១១រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង៨កន្លះព្រឹក មានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជំម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**ដើម្បីជំនុំជម្រះលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ០៤៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ មានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] ម៉េងឈួ ភេទប្រុស អាយុ ២៧ឆ្នាំ កើតថ្ងៃទី០៨.០៤.១៩៩៤ សញ្ជាតិខ្មែរ មុខរបរលក់ដូរ កើតនៅ[redacted] ខេត្តកំពង់ចាម កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] ស៊ីវហេង គ្មានកូន ឪពុកឈ្មោះ [redacted] សារ៉េត (រ) ម្តាយឈ្មោះ [redacted] ភក្តី (ស) ទោសពីមុនគ្មាន កម្រិតវប្បធម៌ថ្នាក់ទី៦ ថ្មី។

ជាប់ចោទពីបទ **នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅចំណុចច្រករបៀងក្រោយកាស៊ីណូលីមហេង ស្ថិតនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**បានឃើញ**

-ដីកាសន្និដ្ឋានស្ថាពរលេខ ០៦១ អ.យ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់អយ្យការអម សាលាដំបូងខេត្តឧត្តរមានជ័យ។

-ដីកាដំណោះស្រាយលេខ ០៧០ ត.ព្រ/២១ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់សាលា ដំបូង ខេត្តឧត្តរមានជ័យ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ បានឆ្លើយសារភាពថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួនគ្រាន់តែចូលទៅលក់ដូរនៅក្នុងផ្សារថៃជាមួយប្រពន្ធ និង បងប្អូនរបស់ខ្លួនតែប៉ុណ្ណោះ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនគឺ ជាប៉ូលីសរបស់ខ្មែរជាអ្នកចាប់ខ្លួន។ មុនពេលដែលសមត្ថកិច្ចឃាត់ខ្លួនគឺ ខាងម្ចាស់ផ្សារនៅថៃបានទាក់ទងឱ្យខ្លួនទៅមើលឥវ៉ាន់របស់ខ្លួនក្នុងផ្សារថៃ ពីព្រោះគេត្រូវការបិទផ្សារនិង រុះ រើតូបមួយចំនួន ដោយសារវិបត្តិកូវីដ។ ខ្លួនមិនបាននាំមនុស្សឆ្លងដែនដោយខុសច្បាប់ឡើយ ពីព្រោះ អ្នកដែលទៅជាមួយខ្លួនគឺ ជាគ្រួសាររបស់ខ្លួនទៅបើកតូបនៅផ្សារថៃជាមួយខ្លួនតែប៉ុណ្ណោះ។

-សេចក្តីថ្លែងការណ៍របស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទគឺ មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែល បានចោទប្រកាន់ដែលអាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ នាំចេញដោយមិន ស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃ ច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ តំណាងអយ្យការប្តឹងសុំតុលា ការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់កំណត់។

-សេចក្តីថ្លែងការណ៍របស់មេធាវីការពារសិទ្ធិជនជាប់ចោទលោក [redacted] បានឆ្លើយថា៖ កូនក្តីរបស់ខ្លួនចូលទៅ ក្នុងប្រទេសថៃជាមួយគ្រួសាររបស់គេតែប៉ុណ្ណោះ មិនមានចេតនាទុច្ចរិតក្នុងការ នាំមនុស្សឆ្លងដែនដោយខុសច្បាប់ឡើយ។ ក្នុងវិបត្តិកូវីដនេះប្រទេសថៃបានជូនដំណឹងមកអាជីវករខ្មែរ ទាំងអស់ដែលមានតូប លក់នៅក្នុងផ្សារចុងចមប្រទេសថៃ ឱ្យទៅរៀបចំឥវ៉ាន់របស់ខ្លួនពីព្រោះអាជ្ញាធរថៃ ត្រូវការបិទផ្សារជាបណ្តោះអាសន្ន ដើម្បីរាំងស្ទះការរីករាលដាលនៅជម្ងឺកូវីដ។ ដូច្នេះបន្ទាប់ពីកូនក្តីរបស់ ខ្លួនបានដឹងនូវដំណឹងភ្លាម ខ្លួននឹងក្រុមគ្រួសារក៏បានចូលទៅប្រទេសថៃដើម្បីរៀបចំទុកដាក់ឥវ៉ាន់ របស់ខ្លួនយកមកប្រទេសកម្ពុជាវិញ ពីព្រោះខ្លាចអាជ្ញាធរថៃរុះរើឥវ៉ាន់ទាំងអស់នោះខូច។ នៅពេល ដែលកូនក្តីរបស់ខ្លួននឹង ក្រុមគ្រួសារចូលទៅប្រទេសថៃ ស្រាប់តែមានសមត្ថកិច្ចកម្ពុជាឃាត់សួរនាំ និង បញ្ជូនសំណុំរឿងមកតុលាការតែម្តង។ កូនក្តីរបស់ខ្លួនមិនមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់ឡើយ ពោលមូលហេតុដែលកូនក្តីរបស់ខ្លួនចូលទៅប្រទេសថៃនោះគឺ ដោយសារ តែកូនក្តីរបស់ខ្លួនមិន បានដឹងអំពីបំរាមរបស់រាជរដ្ឋាភិបាលក្នុងការឆ្លងដែនក្នុងអំឡុងពេលកូវីដ ហើយ ម្យ៉ាងទៀតដោយសារតែកូនក្តីរបស់ខ្លួន មានការបារម្ភអំពីឥវ៉ាន់របស់ខ្លួននៅក្នុងផ្សារប្រទេសថៃខ្លាច



Scanned with CamScanner

អាជ្ញា ធរថៃរុះរើទើប ខ្លួននិងក្រុមគ្រួសារសម្រេចចិត្តចូលទៅផ្សាររុងចម ដើម្បីរៀបចំឥវ៉ាន់របស់ខ្លួនក្នុងតូប យកមកកម្ពុជាវិញ។ ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំតុលាការមេត្តាពិនិត្យពិចារណាសម្រេច ឱ្យកូនក្តី របស់ខ្លួនបានរួចផុតពីការចោទប្រកាន់ផង។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធក្នុងសំណុំរឿង

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

តុលាការក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-ជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ បានឆ្លើយសារភាពៈ ខ្លួនមិនបានប្រព្រឹត្តដូចការចោទ ប្រកាន់ឡើយ។ ខ្លួនគ្រាន់តែចូលទៅផ្សាថៃជាមួយប្រពន្ធ និង បងប្អូន ដើម្បីទៅរៀបចំឥវ៉ាន់ក្នុងតូបរបស់ ខ្លួនទៅក្នុងផ្សាថៃតែប៉ុណ្ណោះ។ មុនពេលដែលសមត្ថកិច្ចឃាត់ខ្លួនគឺ ខាងម្ចាស់ផ្សារនៅថៃបានទាក់ទងឱ្យ ខ្លួនទៅមើលឥវ៉ាន់របស់ខ្លួនក្នុងផ្សាថៃ ពីព្រោះគេត្រូវការបិទផ្សានិងរុះរើតូបមួយចំនួនដោយសារវិបត្តិកូវីដ។ ខ្លួនមិនបាននាំមនុស្សឆ្លងដែនដោយខុសច្បាប់ឡើយ ពីព្រោះអ្នកដែលទៅជាមួយខ្លួនគឺ ជាគ្រួសាររបស់ ខ្លួនទៅបើកតូប ដើម្បីរៀបចំឥវ៉ាន់នៅផ្សារថៃជាមួយខ្លួនតែប៉ុណ្ណោះ។

-ផ្អែកតាមចម្លើយសាក្សីឈ្មោះ [redacted] ស៊ីវហេង នៅដំណាក់កាលស៊ើបសួរបានឆ្លើយថាៈ ខ្លួន នឹងបងស្រីរបស់ខ្លួនពីរនាក់ទៀត ព្រមទាំងឈ្មោះ [redacted] ម៉េងឈួ ដែលត្រូវជាសង្សាររបស់ខ្លួនមានតូបនៅក្នុងផ្សាររុងចមនៅប្រទេសថៃ។ ផ្សារដែលពួកខ្លួនលក់ឥវ៉ាន់នៅប្រទេសថៃ នោះគេត្រូវការរុះរើតូបមួយ ចំនួនដោយសារវិបត្តិកូវីដ ដោយសារខ្លាចខូចឥវ៉ាន់ទើបឈ្មោះ [redacted] ម៉េងឈួ បានបបួលខ្លួននិងបងស្រីពីរ នាក់ទៀតទៅមើលឥវ៉ាន់នៅផ្សារក្នុងប្រទេសថៃទាំងអស់គ្នា។ កាលដែលពួកខ្លួននាំគ្នាចូលទៅប្រទេស ថៃនោះគឺ មិនមានគោលបំណងអ្វីនោះទេពោលគឺ គ្រាន់តែចង់ទៅមើលឥវ៉ាន់ក្នុងតូបរបស់ខ្លួនតែប៉ុណ្ណោះ។

-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និង ចម្លើយរបស់សាក្សីឈ្មោះ [redacted] ស៊ីវហេង ឃើញថា មានភាពស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ គឺមិនបានប្រព្រឹត្ត អំពើ នាំមនុស្សដោយខុសច្បាប់សម្រាប់ឆ្លងដែននោះទេ ពោលគឺ ជនជាប់ចោទ និង សាក្សីបានបបួល គ្នាចូលទៅប្រទេសថៃ ដើម្បីមើលឥវ៉ាន់របស់ខ្លួនដែលម្ចាស់ផ្សារបានជូនដំណឹងឱ្យទៅមើលឥវ៉ាន់ទាំង អស់របស់ពួកគេ ដោយសារផ្សារពួកគេមានតូបលក់ឥវ៉ាន់នោះ ហើយតូបឥវ៉ាន់ក្នុងផ្សារនោះនឹងត្រូវ អាជ្ញាធរថៃរុះរើ និង បិទ តូបមួយចំនួនដោយសារវិបត្តិកូវីដ។



Scanned with CamScanner

-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ និងចម្លើយរបស់សាក្សីអាច បញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ ពិតជាមិនមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើ នាំមនុស្សដោយខុសច្បាប់សម្រាប់ឆ្លងដែន ក្នុងគោលបំណងចង់ទទួលផលប្រយោជន៍ពីការប្រព្រឹត្តអំពើរបស់ខ្លួនឡើយ។

-ផ្អែកតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ឃើញថា អំពើនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន គឺសំដៅលើជនណាដែលបាននាំជន ដទៃទៀតចេញមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែ ចំពោះអង្គហេតុដែលបានចោទប្រកាន់មកនេះគឺ ជនជាប់ចោទឈ្មោះ វ៉េត ម៉េងឈួ មិនបាននាំជនរង គ្រោះឆ្លងដែន ដើម្បីទទួលបានផលប្រយោជន៍ពីអំពើនោះឡើយ ពោលគឺ ជនជាប់ចោទ និង សាក្សី ឈ្មោះ ខួយ ស៊ីវហេង ព្រមទាំងបងស្រីចំនួនពីរនាក់ទៀត គ្រាន់តែបបួលគ្នាទៅប្រទេសថៃ ដើម្បីមើលឥវ៉ាន់ក្នុងតូបរបស់ខ្លួនក្នុងផ្សារថៃតែប៉ុណ្ណោះ។

-មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ ភេទប្រុស កើតឆ្នាំ ១៩៩៨ (សាវតាជាតិដូចខាងលើ)ពីបទ នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅចំណុចច្រករបៀងក្រោយកាស៊ីណូលីមហេង ស្ថិតនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ដោយផ្អែកតាមមាត្រា ៣៥០ និងមាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-ចំពោះវត្ថុតាងរួមមាន៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចំនួន ០១ សន្លឹក និងទូរស័ព្ទដៃម៉ាក MI ពណ៌មាស ចំនួន ០១គ្រឿង គប្បីតុលាការពិនិត្យពិចារណាសម្រេចជាសមត្ថកិច្ចដោយផ្អែកតាមមាត្រា ៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសាលាដំបូងខេត្តឧត្តរមានជ័យ

## សម្រេច៖

១.ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ ភេទប្រុស កើតឆ្នាំ១៩៩៨ (មានសាវតាជាតិដូចខាង លើ) បានរួចផុតពីបទចោទប្រកាន់ ពីបទ នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅចំណុចច្រករបៀងក្រោយកាស៊ីណូលីមហេង ស្ថិតនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។



Scanned with CamScanner

២.វត្ថុតាងរួមមាន៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចំនួន ០១ សន្លឹក និង ទូរស័ព្ទដៃម៉ាក MI ពណ៌មាស ចំនួន ០១គ្រឿង ត្រូវរឹបអូសប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉េងឈួ ។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

**បានឃើញ**
ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តឧត្តរមានជ័យ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តឧត្តរមានជ័យ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner